**ជនជាតិភាគតិច**

- រដ្ឋគួរដាក់ចេញនូវវិធានការបន្ថែម ដើម្បីដោះស្រាយផលប៉ះពាល់មិនសមាមាត្រនៃវិបត្តិសុខភាព ដោយសារជំងឺកូវីដ-១៩ ដែលជនជាតិភាគតិចអាចទទួលរង ដោយសារតែវាជាតំបន់ដាច់ស្រយាល ឬ តំបន់ដែលពួកគេរស់នៅ ជារឿយៗ លទ្ធភាពទទួលបានទំនិញ និងសេវាជាមូលដ្ឋានផ្សេងៗ នៅមាន កំណត់។ ជនជាតិភាគតិច ច្រើនតែរស់នៅក្នុងស្ថានភាពលំនៅឋានចង្អៀតខ្លាំង ធ្វើឱ្យការនៅឃ្លាតពីគ្នា ខាងរាងកាយ និងដោយខ្លួនឯងកាន់តែពិបាក។ លទ្ធភាពប្រើប្រាស់ឌីជីថលមានកំណត់ និងចន្លោះខ្វះ ខាតការអប់រំរបស់ឪពុកម្តាយ ក៏អាចធ្វើឱ្យការសិក្សានៅផ្ទះមានការលំបាកថែមទៀត។
- ជនទាំងឡាយដែលជាសមាជិកក្រុមជនជាតិភាគតិច អាចនឹងត្រូវបានគេផាត់ចេញពីកិច្ចគាំពារសុខភាព ព្រោះពួកគេខ្វះធនធាន ឬឯកសារផ្លូវការ ឬដោយសារតែការមាក់ងាយ (ស្ទិកម៉ា) ឬការរើសអើង។ រដ្ឋ ទាំងឡាយ គួរធានាដល់ជនជាតិភាគតិចនូវសិទ្ធិទទួលបានកិច្ចគាំពារសុខភាព រួមទាំង អ្នកដែលគ្មាន ប័ណ្ណធានារ៉ាប់រងសុខភាព ឬឯកសារបញ្ជាក់អត្តសញ្ញាណ។